អត្ថបទបកប្រែក្រៅផ្លូវការ

# សេចក្តីថ្លែងការណ៍រួម
# ស្តីពីការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី
# រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន

* * * * * * * * *

តបតាមការអញ្ជើញរបស់រដ្ឋាភិបាលចិន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ពីថ្ងៃទី០៩ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣។

ក្នុងឱកាសទស្សនកិច្ចនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាជាមួយ **ឯកឧត្តម ប្រធានាធិបតី ស៊ី ជីនពីង** និងធ្វើការផ្លាស់ប្តូរទស្សនៈគ្នាយ៉ាងស៊ីជម្រៅ អំពីការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន និងបញ្ហាតំបន់ និងអន្តរជាតិ ដែលជាប្រយោជន៍រួម ដើម្បីកំណត់ទិសដៅ នៃទំនាក់ទំនងកម្ពុជា-ចិន នាពេលអនាគត។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តមនាយករដ្ឋមន្ត្រី លី ខឺឈាង** និងជួបជាមួយ **ឯកឧត្តម លី ជានស៊ូ** ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសភាតំណាងប្រជាជនចិន។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះមិត្តភាពដែកថែបមិនអាចបំបែកបានកម្ពុជា-ចិន ដែលត្រូវបានពូនជ្រុំយ៉ាងយកចិត្តទុកដាក់ ដោយថ្នាក់ដឹកនាំជំនាន់មុន នៃប្រទេសទាំងពីរ និងបន្តរីកចម្រើនកាន់តែខ្លាំងក្លា ក្នុងរយៈពេល ៦៥ ឆ្នាំ ក្រោយពីការបង្កើតទំនាក់ទំនងការទូត ដែលបង្ហាញអំពីទំនាក់ទំនងអន្តរជាតិបែបថ្មី។ ក្នុងបរិបទ នៃការផ្លាស់ប្តូរ និងបញ្ហាប្រឈមនានាយ៉ាងខ្លាំងក្លា នៅក្នុងពិភពលោក សារសំខាន់ជាយុទ្ធសាស្ត្រ នៃទំនាក់ទំនងកម្ពុជា-ចិន កាន់តែមានភាពចាំបាច់ថែមទៀត។ មិនថាស្ថានភាពអន្តរជាតិមានការផ្លាស់ប្តូរយ៉ាងណា ភាគីទាំងពីរនឹងធ្វើឱ្យកាន់តែស៊ីជម្រៅឥតងាករេ នូវមិត្តភាពដែកថែបយ៉ាងជិតស្និទ្ធ និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាក់ស្តែងឈ្នះ-ឈ្នះ ដើម្បីផលប្រយោជន៍ទៅវិញទៅមក សំដៅជំរុញការកសាងសហគមន៍វាសនារួមសម្រាប់មនុស្សជាតិ។ ភាគីទាំងពីរបានប្រកាសបើកព្រឹត្តិការណ៍ «**ឆ្នាំមិត្តភាពកម្ពុជា-ចិន**» ដើម្បីអបអរសាទរខួបលើកទី ៦៥ នៃការបង្កើតទំនាក់ទំនងការទូត និងឆ្នាំមិត្តភាពឆ្ពោះទៅយុគសម័យថ្មី នៃការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់ និងស្តង់ដារខ្ពស់ ដើម្បីបន្តថែរក្សាទំនាក់ទំនងមិត្តភាពដែកថែប ដែលជារតនសម្បត្តិដ៏មានតម្លៃបំផុត គ្រប់ជំនាន់។

១. ភាគីកម្ពុជាបានអបអរសាទរយ៉ាងកក់ក្តៅសាជាថ្មី ចំពោះភាពជោគជ័យដ៏ពេញលេញ នៃសមាជជាតិលើកទី ២០ របស់បក្សកុម្មុយនីស្តចិន និងការបោះឆ្នោតជ្រើសតាំង **ឯកឧត្តម ស៊ី ជីនពីង** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិនលើកទី ២០ និងបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលរបស់ចិន នៅក្នុងទសវត្សរ៍ នៃយុគសម័យថ្មី និងទំនើបកម្មចិន ដែលបានផ្តល់នូវជម្រើស

មាគ៌ាទំនើបកម្ម ដែលរួមចំណែកយ៉ាងធំធេងដល់គតិបណ្ឌិត ដំណោះស្រាយ និងភាពរឹងមាំ ដើម្បីដោះស្រាយបញ្ហារួមសម្រាប់មនុស្សជាតិ។ ភាគីកម្ពុជាបានសម្តែងជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន ដែលមានសមមិត្ត **ស៊ី ជីនពីង** ជាស្នូល ចិននឹងសម្រេចបានគោលដៅ ១០០ ឆ្នាំ ទីពីរ ក្នុងការកសាងប្រទេសសង្គមនិយមទំនើបដ៏អស្ចារ្យលើគ្រប់វិស័យ ក្លាយជាប្រទេសដ៏រុងរឿង តាមរយៈការធ្វើទំនើបកម្មចិន ដែលរួមចំណែកកាន់តែធំធេងដល់បុព្វហេតុដ៏ឧត្តុងឧត្តម នៃសន្តិភាព និងការអភិវឌ្ឍសម្រាប់មនុស្សជាតិ។

២. ភាគីចិនបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលគួរឱ្យកត់សម្គាល់របស់កម្ពុជា ក្នុងការរក្សាស្ថិរភាពជាតិ វិបុលភាព និងការកើនឡើងនូវឥទ្ធិពលរបស់កម្ពុជានៅលើឆាកអន្តរជាតិ។ ចិនជឿជាក់ថា ក្រោមម្លប់របស់ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាប្រមុខ កម្ពុជានឹងបន្តសម្រេចបាននូវវឌ្ឍនភាពថ្មីៗ ក្នុងការអភិវឌ្ឍជាតិ និងសុខុមាលភាពជូនប្រជាពលរដ្ឋ ព្រមទាំងដើរតួនាទីកាន់តែធំធេង ក្នុងការថែរក្សាសន្តិភាព និងវិបុលភាពនៅក្នុងតំបន់ និងពិភពលោក។

៣. ភាគីទាំងពីរបានសង្កត់ធ្ងន់ថា ការគាំទ្រគ្នាទៅវិញទៅមកលើបញ្ហា ដែលជាផលប្រយោជន៍ស្នូលរវាងគ្នានិងគ្នា ពិតជាមានសារសំខាន់ណាស់ សម្រាប់សហគមន៍វាសនារួមកម្ពុជា-ចិន។ ភាគីចិនបានអះអាងសាជាថ្មីអំពីការគាំទ្រឥតងាករេចំពោះជម្រើស នៃមាគ៌ាអភិវឌ្ឍន៍របស់ប្រជាជនកម្ពុជាស្របទៅនឹងលក្ខខណ្ឌជាតិរបស់កម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីរក្សាឯករាជ្យភាព អធិបតេយ្យភាព សន្តិសុខ និងផលប្រយោជន៍នៃការអភិវឌ្ឍ និងលើកកម្ពស់ជាបន្តបន្ទាប់ នៃរបៀបវារៈនយោបាយជាតិសំខាន់ៗរបស់កម្ពុជា ហើយប្រឆាំងដាច់ខាត ចំពោះការជ្រៀតជ្រែកពីបរទេសចូលកិច្ចការផ្ទៃក្នុងកម្ពុជា។

ភាគីកម្ពុជាបានអះអាងសាជាថ្មីអំពីការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវ «គោលនយោបាយចិនមួយ»។ រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន គឺជារដ្ឋាភិបាលស្របច្បាប់តែមួយគត់ តំណាងឱ្យប្រទេសចិនទាំងមូល។ តៃវ៉ាន់ គឺជាផ្នែកមួយ ដែលមិនអាចកាត់ផ្តាច់ចេញពីទឹកដីរបស់ចិន ហើយបញ្ហាតៃវ៉ាន់ជាកិច្ចការផ្ទៃក្នុងរបស់ចិន ដែលមិនអាចត្រូវបានជ្រៀតជ្រែកពីកម្លាំងខាងក្រៅបានឡើយ។ កម្ពុជាប្រឆាំងការប៉ុនប៉ងនានា ក្នុងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ចិន ឬដើម្បីរារាំង និងទប់ស្កាត់ប្រទេសចិន ក្រោមហេតុផលតៃវ៉ាន់ ឬសកម្មភាពបំបែកខ្លួនគ្រប់ទម្រង់ដើម្បីទាមទារ «ឯករាជ្យភាពតៃវ៉ាន់» និងសូមគាំទ្រយ៉ាងម៉ឺងម៉ាត់នូវកិច្ចប្រឹងប្រែងនានារបស់ចិន ដើម្បីសម្រេចបាននូវការបង្រួបបង្រួមជាតិ។ កម្ពុជានឹងមិនបង្កើតទំនាក់ទំនងផ្លូវការក្នុងទម្រង់ណាក៏ដោយ ជាមួយតៃវ៉ាន់ឡើយ។

ភាគីទាំងពីរបានឯកភាពថា បញ្ហាពាក់ព័ន្ធនឹងស៊ីនជាំងមិនមែនជាបញ្ហាសិទ្ធិមនុស្ស ប៉ុន្តែជាការបង្ក្រាបអំពើភេរវកម្ម ភាពជ្រុលនិយម និងការផ្តាច់ខ្លួននិយម។ ភាគីកម្ពុជាបានបញ្ជាក់ជាថ្មីអំពីការប្រឆាំងជាដាច់ខាត ចំពោះការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ចិន ដោយប្រើប្រាស់បញ្ហាពាក់ព័ន្ធនឹងស៊ីនជាំង។

ភាគីទាំងពីរបានឯកភាពថា ការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិមនុស្សចាំបាច់ត្រូវផ្សារភ្ជាប់ជាមួយនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងលក្ខខណ្ឌជាតិជាក់ស្តែង។ ភាគីទាំងពីរបានប្រឆាំងដាច់ខាតចំពោះការធ្វើនយោបាយ និងយកបញ្ហាសិទ្ធិមនុស្សជាឧបករណ៍ ការអនុវត្តស្តង់ដារពីរ ការបំពានតម្លៃប្រជាធិបតេយ្យ ដើម្បីជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសអធិបតេយ្យ ឬធ្វើឱ្យមានការបែកបាក់ និងប្រឈមមុខដាក់គ្នា ក្រោមហេតុផលគាំពារប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ឬការដាក់កំហិតអំពីឆន្ទៈរបស់ប្រទេសមួយទៅលើប្រទេសដទៃទៀត។

៤. ភាគីទាំងពីរបានឯកភាពជំរុញការប្រាស្រ័យទាក់ទងកម្រិតខ្ពស់ តាមទម្រង់នានា ដូចជាទស្សនកិច្ចទ្វេភាគី ជំនួបតាមប្រព័ន្ធវីដេអូ សារ និងលិខិតនានា ដើម្បីលើកកម្ពស់ការប្រាស័យទាក់ទងគ្នាជាយុទ្ធសាស្ត្រ និងទំនុកចិត្តនយោបាយ តាមរយៈការផ្លាស់ប្តូរស៊ីជម្រៅលើបញ្ហាទ្វេភាគី តំបន់ និងអន្តរជាតិសំខាន់ៗឱ្យទាន់ពេលវេលា សំដៅជំរុញទំនាក់ទំនងកម្ពុជា-ចិនឱ្យស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ។

៥. ភាគីទាំងពីរបានឯកភាពបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការត្បូងពេជ្រ ដោយមានវិស័យអាទិភាពចំនួន ៦ រួមមានៈ កិច្ចសហប្រតិបត្តិការនយោបាយ-គុណភាពនិងសមត្ថភាពផលិតកម្ម-កសិកម្ម-ថាមពល-សន្តិសុខ និងការផ្លាស់ប្តូរប្រជាជននិងប្រជាជន។

ភាគីទាំងពីរបានឯកភាពប្រើប្រាស់ឱ្យបានពេញលេញ នូវតួនាទីរបស់គណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ចរចា និងចុះហត្ថលេខាលើផែនការសកម្មភាពថ្មី ស្តីពីការកសាងសហគមន៍វាសនារួមកម្ពុជា-ចិនឱ្យបានឆាប់ និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងលើកិច្ចសហប្រតិបត្តិការជាក់ស្តែងលើវិស័យនានា។ ភាគីទាំងពីរបានឯកភាពផ្លាស់ប្តូរ និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងគណបក្សនយោបាយលើវិស័យនានា និងគ្រប់កម្រិត បង្កើនការផ្លាស់ប្តូរលើផ្នែកអភិបាលកិច្ច និងការបណ្តុះបណ្តាលមន្ត្រី ជំរុញកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានសមភាគីលើការត្រួតពិនិត្យការរៀបចំ និងការផ្សព្វផ្សាយ និងជំរុញការផ្លាស់ប្តូរយុវជន ប្រកបដោយភាពស្និទ្ធស្នាល។ ធ្វើឱ្យស៊ីជម្រៅការផ្លាស់ប្តូររវាងសភាតំណាងប្រជាជនចិន គណៈកម្មាធិការជាតិ នៃសភាប្រឹក្សានយោបាយប្រជាជនចិន និងរដ្ឋសភា និងព្រឹទ្ធសភាកម្ពុជា។ អនុវត្តកិច្ចព្រមព្រៀង ស្តីពីការជំរុញកិច្ចសហប្រតិបត្តិការក្នុងការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី រវាងក្រសួងការបរទេសទាំងពីរ ដើម្បីការពារផលប្រយោជន៍រួម។

ភាគីទាំងពីរបានឯកភាពធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការ និងការបន្សុីគ្នាជាយុទ្ធសាស្ត្ររវាងគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីធានាសុវត្ថិភាព នៃគម្រោង និងបុគ្គលិក ព្រមទាំងផ្តល់តួនាទីឱ្យកាន់តែសំខាន់ដល់យន្តការការងារកម្ពុជា-ចិន សម្រាប់កិច្ចសហប្រតិបត្តិការវិនិយោគ និងសមត្ថភាពផលិតកម្ម។ ពិនិត្យលទ្ធភាពអភិវឌ្ឍន៍ «ច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា» ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ ក្នុងការអភិវឌ្ឍខេត្តព្រះសីហនុឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណងគំរូមួយ។ កសាងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ជាគម្រោង

លេចធ្លោ និងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ដើម្បីទាក់ទាញសហគ្រាសចិន ដែលមានសមត្ថភាពបន្ថែមទៀត ក្នុងការបង្កើនការវិនិយោគនៅកម្ពុជា ពិនិត្យលទ្ធភាពលើសហប្រតិបត្តិការក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន បណ្ដាញអគ្គិសនី បណ្ដាញខ្សែកាបអុបទិក ឃ្លាំងស្តុកទំនិញ និងកស្តុភារកម្ម ដើម្បីបង្កើនប្រសិទ្ធភាពសមាហរណកម្ម នៃកិច្ចសហប្រតិបត្តិការសមត្ថភាពផលិតកម្មកម្ពុជា-ចិន ដែលមានលក្ខណៈចម្រុះ។

ចិនគាំទ្រកម្ពុជាលើការងារដំបូង នៃការធ្វើផែនការរៀបចំផ្លូវដែក ការរចនា និងការសិក្សាសមិទ្ធលទ្ធភាព សំដៅលើកកម្ពស់គម្រោង និងការសាងសង់ផ្លូវដែក ដើម្បីផលប្រយោជន៍ជីវភាពប្រជាជន ដែលរស់នៅតាមបណ្ដោយផ្លូវដែកនេះ។ ភាគីទាំងពីរទទឹងរង់ចាំការតភ្ជាប់ផ្លូវដែកកម្ពុជា និងផ្លូវដែកចិន-ឡាវ-ថៃ ក្នុងពេលឆាប់ៗនេះ។

ភាគីទាំងពីរបានឯកភាពអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នា ស្ដីពីផែនការកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា-ចិន (២០២៣-២០២៥)។ ជំរុញការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវថ្នល់ ស្ពាន អាងស្តុកទឹក ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ និងខ្សែកាបអុបទិកក្រោមបាតសមុទ្រ។ អនុវត្តគម្រោងផ្លូវជនបទនានា ការផ្គត់ផ្គង់ទឹក សាលារៀន និងគម្រោងវេជ្ជសាស្ត្រនានា នៅកម្ពុជា ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ភាគីកម្ពុជាបានថ្លែងអំណរគុណចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ប្រទេសចិន ក្នុងទម្រង់នានា សម្រាប់ការអនុវត្តគម្រោងនានា ពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងបច្ចេកទេស និងគម្រោងអភិវឌ្ឍន៍ធនធានមនុស្ស នៅកម្ពុជា។

ភាគីទាំងពីរបានឯកភាពពិនិត្យលទ្ធភាពបង្កើត «ច្រករបៀងមច្ឆា និងអង្ករ» ដែលមានទីតាំងនៅភាគពាយព្យ នៃប្រទេសកម្ពុជា និងនៅតំបន់បឹងទន្លេសាប អភិវឌ្ឍកសិកម្មអេកូឡូស៊ីទំនើប នៅក្បែរបឹងទន្លេសាប។ ពន្លឿនការធ្វើផែនការអភិវឌ្ឍន៍កសិកម្មទំនើបរបស់កម្ពុជា ពិនិត្យលទ្ធភាពលើកិច្ចសហប្រតិបត្តិការកសិកម្មឌីជីថល និងគាំទ្រការលើកកម្ពស់លើវិស័យវារីវប្បកម្ម ចម្ការត្រូពិក និងវិស័យសក្ដានុពលផ្សេងទៀតរបស់កម្ពុជា។ លើកកម្ពស់កិច្ចសហប្រតិបត្តិការត្រួតពិនិត្យគយ និងចត្តាឡីស័ក និងជំរុញយ៉ាងសកម្មក្នុងការនាំចូលកសិផលកម្ពុជា ដែលមានគុណភាពខ្ពស់ បន្តជំរុញអន្តរតភ្ជាប់ «ច្រកចេញចូលតែមួយ» ដើម្បីជំរុញពាណិជ្ជកម្មទ្វេភាគី។ ប្រើប្រាស់ឱ្យបានពេញលេញនូវកិច្ចព្រមព្រៀង RCEP និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ព្រមទាំងជំរុញការចរចាដំឡើងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ ក៏ដូចជាវេទិកានានា រួមទាំងពិព័រណ៍នាំចូលអន្តរជាតិចិន ពិព័រណ៍នាំចូល និងនាំចេញចិន និងពិព័រណ៍អាស៊ាន-ចិន ក៏ដូចជាយន្តការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឌីជីថលទ្វេភាគី ដើម្បីបង្កើនការប្រកួតប្រជែង និងប្រជាប្រិយភាព នៃផលិតផលកម្ពុជានៅក្នុងប្រទេសចិន និងជំរុញពាណិជ្ជកម្មទ្វេភាគីឱ្យឈានដល់កម្រិតខ្ពស់ថ្មីមួយទៀត។ លើកទឹកចិត្តប្រជាជននៅតាមមូលដ្ឋាន ក្នុងប្រទេសទាំងពីរ ដើម្បីដើរតួនាទីសំខាន់រៀងៗខ្លួនឱ្យបានពេញលេញ សំដៅបង្កើនកិច្ចសហប្រតិបត្តិការជាក់ស្ដែងលើវិស័យកសិកម្ម សេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ភាគីទាំងពីរបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការលើវិស័យថាមពលវារីអគ្គិសនី ថាមពលដើរដោយពន្លឺ និងប្រភពថាមពលស្អាតដទៃទៀត និងស្វែងរកដំណោះស្រាយកិច្ចសហប្រតិបត្តិការថាមពលស្ថិរភាព និងបៃតង ដែលអាចពឹងផ្អែកបាន។ ជំរុញការបង្កើតគម្រោងតំបន់បង្ហាញការបញ្ចេញកាបូនតិចកម្ពុជា-ចិន នៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ស្តីពីការប្រែប្រួលអាកាសធាតុ នៅខេត្តព្រះសីហនុ។ កិច្ចសហប្រតិបត្តិការលើវិស័យបរិស្ថាន និងអេកូឡូស៊ីនឹងត្រូវបានរំលេចកាន់តែច្រើនឡើងនៅក្នុងកិច្ចសន្ទនាគោលនយោបាយ ការស្រាវជ្រាវរួម និងការកសាងសមត្ថភាព ក៏ដូចជាការបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងកិច្ចគាំពារបរិស្ថាន និងអេកូឡូស៊ី នៅកម្ពុជា ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរទស្សនៈ យុទ្ធសាស្ត្រ បទបញ្ញត្តិ និងស្តង់ដារ។

ភាគីទាំងពីរបានឯកភាពបង្កើនទំនាក់ទំនងរវាងកងទ័ពរំដោះប្រជាជនចិន និងកងយោធពលខេមរភូមិន្ទ គ្រប់លំដាប់ថ្នាក់ ដោយចាប់យកសក្តានុពល នៃយន្តការកិច្ចសហប្រតិបត្តិការ តាមរយៈការពង្រឹងការផ្លាស់ប្តូរកងកម្លាំងសមភាគី និងសមយុទ្ធ និងការហ្វឹកហ្វឺនរួមគ្នារវាងយោធាទាំងពីរ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែង ក្នុងវិស័យកសាងសមត្ថភាព ការបណ្តុះបណ្តាលយោធា ភស្តុភារកម្ម និងបរិក្ខារ ព្រមទាំងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ក្នុងកិច្ចការសន្តិសុខពហុភាគី។

ភាគីទាំងពីរបានឯកភាពបន្តកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានរវាងមន្ត្រីអនុវត្តច្បាប់ ដោយផ្តោតការយកចិត្តទុកដាក់លើការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ការទប់ស្កាត់ «បដិវត្តន៍ពណ៌» ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងគ្រឿងញៀន ការឆបោកតាមប្រព័ន្ធទូរគមនាគមន៍ ការលេងល្បែងស៊ីសងឆ្លងដែនខុសច្បាប់ និងអំពើជួញដូរមនុស្ស និងការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់។ លើកកម្ពស់ការពង្រឹងការិយាល័យសម្របសម្រួល និងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់កម្ពុជា-ចិន។

ភាគីកម្ពុជាបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ចិន ក្នុងការបង្កើនប្រសិទ្ធភាព និងកែសម្រួលគោលនយោបាយទប់ស្កាត់ និងគ្រប់គ្រងជំងឺកូវីដ-១៩ ផ្អែកតាមការវិវត្តនៃស្ថានការណ៍ ដែលបង្កើតនូវលក្ខខណ្ឌប្រសើរសម្រាប់ការផ្លាស់ប្តូរប្រជាជន និងប្រជាជន ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងរបៀបរៀបរយ រវាងប្រទេសចិន និងបណ្តាប្រទេសផ្សេងៗ ដើម្បីផ្តល់ផលប្រយោជន៍កាន់តែច្រើនដល់សេដ្ឋកិច្ចសកល។ ចិនបានប្រកាសថា កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដំបូង ដែលនឹងទទួលភ្ញៀវទេសចរចិន ព្រមទាំងផ្តល់អាទិភាពក្នុងការស្តារ និងបង្កើនចំនួនជើងហោះហើរត្រង់។ ភាគីកម្ពុជាបានបញ្ជាក់សាជាថ្មីនូវការស្វាគមន៍យ៉ាងកក់ក្តៅដល់ទេសចរចិន និងការប្តេជ្ញាផ្តល់សេវាកម្ម និងសន្តិសុខ ប្រកបដោយគុណភាព។ ភាគីទាំងពីរបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការរវាងសហគ្រាសវប្បធម៌ និងទេសចរណ៍នានា នៃប្រទេសទាំងពីរ ដើម្បីរួមគ្នាបង្កើតផ្លូវទេសចរណ៍ បង្កើតផលិតផលវប្បធម៌ និងទេសចរណ៍ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ ក្នុងការបណ្តុះបណ្តាលបុគ្គលិកវប្បធម៌ និងទេសចរណ៍។

ភាគីទាំងពីរបានឯកភាពអនុវត្តកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រវាងរដ្ឋាភិបាលទាំងពីរ ដោយឈរលើមូលដ្ឋាននៃសមភាព សមធម៌ និង ផលប្រយោជន៍ទៅវិញទៅមក រួមមានការរៀបចំកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-ចិន លើកទី ១ ស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការផ្ទេរបច្ចេកវិទ្យា និងការផ្លាស់ប្តូរប្រជាជន និងប្រជាជន ក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ភាគីទាំងពីរបានឯកភាពដាក់ចេញនូវកិច្ចសន្ទនាគោលនយោបាយអប់រំ គាំទ្រយុវជនកម្ពុជា ទៅសិក្សានៅប្រទេសចិន ហើយគាំទ្រកម្ពុជាធ្វើការអភិវឌ្ឍការបង្រៀនភាសាចិន ជំរុញការបង្កើត វិទ្យាស្ថានខុងជឺថ្មី នៅកម្ពុជា បង្កើនកិច្ចសហប្រតិបត្តិការអប់រំវិជ្ជាជីវៈ និងការផ្លាស់ប្តូរអប់រំឧត្តមសិក្សា។

ភាគីទាំងពីរបានឯកភាពជំរុញគម្រោងជំនួយចិន ក្នុងការជួសជុលព្រះបរមរាជវាំងនៅអង្គរ គាំពារ និងជួសជុលប្រាសាទព្រះវិហារ និងបេតិកភណ្ឌវប្បធម៌នានា និងប្តេជ្ញាធ្វើសកម្មភាពរួម ដើម្បី អភិរក្សបេតិកភណ្ឌវប្បធម៌អាស៊ី ពិភាក្សាបង្កើតក្រុមការងារចម្រុះកម្ពុជា-ចិន ស្តីពីបេតិកភណ្ឌវប្បធម៌ ជំរុញកិច្ចសហប្រតិបត្តិការគ្រប់ផ្នែក។ ភាគីទាំងពីរបានឯកភាពបន្តធ្វើការជាមួយគ្នា ក្នុងវេទិកា នៃ ក្រុមប្រឹក្សាវប្បធម៌អាស៊ី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់សន្តិភាព វិបុលភាព សាមគ្គីភាព និងមិត្តភាព តាមរយៈការយល់ដឹង ការគោរព ទំនុកចិត្ត និងផលប្រយោជន៍ទៅវិញទៅមក និងការតភ្ជាប់អរិយធម៌អាស៊ី។

ចិនគាំទ្រកម្ពុជារៀបចំកីឡាអាស៊ីអាគ្នេយ៍ ឆ្នាំ២០២៣ ហើយនឹងបន្តជួយកម្ពុជា ក្នុងការ បណ្តុះបណ្តាលអត្តពលិក។ កម្ពុជានឹងបញ្ជូនប្រតិភូទៅចូលរួមកីឡា យូនីវើសេដ រដូវក្តៅឆឹងទូ (Chengdu Summer Universiade) និងកីឡាអាស៊ីហាងចូវ។

ភាគីទាំងពីរបានឯកភាពធ្វើឱ្យស៊ីជម្រៅនូវការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការឱសថបុរាណ និងវិស័យសុខាភិបាលដទៃទៀត ជំរុញការបង្កើតមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការឱសថបុរាណចិន កម្ពុជា-ចិន។ ភាគីទាំងពីរគាំទ្រយ៉ាងសកម្មនូវការផ្លាស់ប្តូរប្រជាជន និងប្រជាជន តាមទម្រង់នានា និង ជំរុញអង្គការសង្គមស៊ីវិលអនុវត្តការសិក្សាអរិយធម៌ពីគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការលើ គម្រោងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរប្រជាជន និងប្រជាជន។

៦. ភាគីទាំងពីរបានទទួលស្គាល់គុណតម្លៃរួមរបស់មនុស្សជាតិ ប្រកបដោយសន្តិភាព ការ អភិវឌ្ឍ ភាពមិនលម្អៀង យុត្តិធម៌ ប្រជាធិបតេយ្យ និងសេរីភាព និងបានត្រៀមខ្លួនក្នុងការការពារ ប្រព័ន្ធអន្តរជាតិ ដែលមានអង្គការសហប្រជាជាតិជាស្នូល សណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់អន្តរ ជាតិ និងនិយាមមូលដ្ឋានដែលគ្រប់គ្រងទំនាក់ទំនងអន្តរជាតិ ដូចមានចែងនៅក្នុងគោលបំណង និង គោលការណ៍របស់ធម្មនុញ្ញអង្គការសហប្រជាជាតិ ខណៈដែលប្រឆាំងរាល់គ្រប់ទម្រង់ នៃអនុត្តរភាព និយម នយោបាយអំណាច ឯកតោភាគីនិយម និងប្លុកនយោបាយផ្តាច់មុខ ដែលសំដៅលើប្រទេស ជាក់លាក់នានាណាមួយ។ ប្រទេសទាំងពីរប្តេជ្ញាកសាងទំនាក់ទំនងអន្តរជាតិបែបថ្មី និងជំរុញភាពជា ដៃគូសកល នៃសមភាព បើកចំហ និងកិច្ចសហប្រតិបត្តិការ ឆ្ពោះទៅសម្រេចបានសហគមន៍វាសនា រួមសម្រាប់មនុស្សជាតិ។

ភាគីទាំងពីរបានឯកភាពប្រកាន់ខ្ជាប់នូវពហុភាគីនិយមយ៉ាងពិតប្រាកដ គាំទ្រយ៉ាងពេញទំហឹងលើប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដែលបើកចំហ តម្លាភាព បរិយាប័ន មិនរើសអើងគ្នា និងផ្អែកលើច្បាប់ ដោយយកអង្គការពាណិជ្ជកម្មពិភពលោកជាស្នូល និងត្រៀមខ្លួនរួចជាស្រេចដើម្បីរួមគ្នាលើកកម្ពស់អង្គការពាណិជ្ជកម្មពិភពលោកឱ្យដើរតួនាទីកាន់តែខ្លាំងក្លា ក្នុងអភិបាលកិច្ចសេដ្ឋកិច្ចសកល។ ចិនបានស្វាគមន៍ការចូលរួមរបស់កម្ពុជាក្នុងក្រុមប្រទេសជាមិត្ត នៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល។ កម្ពុជាត្រៀមខ្លួនរួចជាស្រេច ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការ ទាំងកម្រិតទ្វេភាគី និងពហុភាគីលើការអនុវត្តគំនិតផ្តួចផ្តើមនេះ ដើម្បីរួមគ្នាអនុវត្តរបៀបវារៈរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០៣០ សម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាគាំទ្រសំណើរបស់ចិន ក្នុងការបង្កើតគំនិតផ្តួចផ្តើមសន្តិសុខសកល និងត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើការជាមួយចិន ស្តីពីអភិបាលកិច្ចសន្តិសុខសកល ដើម្បីសម្រេចបានសន្តិសុខរួម ប្រកបដោយចីរភាព សហប្រតិបត្តិការ និងគ្រប់ជ្រុងជ្រោយ។

ភាគីចិនបានអបអរសាទរភាពជោគជ័យរបស់កម្ពុជា ក្នុងនាមជាប្រធានអាស៊ាន ឆ្នាំ២០២២ ក្រោមមូលបទ «អាស៊ានរួមគ្នាធ្វើ-ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា» និងបានវាយតម្លៃខ្ពស់ចំពោះតួនាទីជាវិជ្ជមានរបស់កម្ពុជាក្នុងការសម្រេចបាននូវសន្តិភាព ស្ថិរភាព ការអភិវឌ្ឍ និងវិបុលភាពយូរអង្វែងក្នុងតំបន់ និងពិភពលោក។ ភាគីទាំងពីរបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះតំបន់និយមបើកចំហ ដើម្បីឈានទៅការកសាងគេហដ្ឋាន ប្រកបដោយសន្តិភាព សុវត្ថិភាព សន្តិសុខ វិបុលភាព ភាពស្រស់បំព្រង និងមិត្តភាព នៅក្នុងតំបន់ និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយអាស៊ាន-ចិន និងបានឯកភាពលើកកម្ពស់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងជំរុញការកសាងសហគមន៍វាសនារួម សម្រាប់ប្រទេសមេគង្គ-ឡានឆាង ឱ្យកាន់តែជិតស្និទ្ធថែមទៀត។

៧. ភាគីទាំងពីរជឿជាក់ថា ក្រោមកិច្ចប្រឹងប្រែងរួមគ្នា នៃប្រទេសសមាជិកអាស៊ាន និងចិន ស្ថានភាពនៅសមុទ្រចិនខាងត្បូងត្រូវបានរក្សាស្ថិរភាពជារួម។ ប្រទេសទាំងពីរបានអំពាវនាវដល់ភាគីពាក់ព័ន្ធអនុវត្តឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវសេចក្តីប្រកាសស្តីពីការប្រតិបត្តិរបស់បណ្តាភាគី នៅសមុទ្រចិនខាងត្បូង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការលម្ហសមុទ្រ និងសម្រេចឱ្យបានឆាប់នូវក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង ប្រកបដោយសារសំខាន់ និងប្រសិទ្ធភាពឈរលើមូលដ្ឋានការឯកភាពជាឯកច្ឆន្ទទៅវិញទៅមក ដើម្បីកសាងសមុទ្រចិនខាងត្បូង ទៅជាសមុទ្រសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការ។ រាល់ការប៉ុនប៉ងណាមួយ ក្នុងការប្រើប្រាស់បញ្ហាសមុទ្រចិនខាងត្បូង ដើម្បីបំផ្លាញសន្តិភាព ស្ថិរភាព និងការជឿជាក់ក្នុងតំបន់ពុំមានលទ្ធផលល្អឡើយ ហើយគួរតែត្រូវជៀសវាង។

៨. ភាគីទាំងពីរបានសម្តែងសេចក្តីសោមនស្សរីករាយ ចំពោះលទ្ធផល នៃដំណើរទស្សនកិច្ចនេះ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជូនថ្នាក់ដឹកនាំ និងប្រជាជនចិន ចំពោះបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និងប្រកបដោយភាពស្និទ្ធស្នាល ព្រមទាំងបានអញ្ជើញ **ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង** និងថ្នាក់ដឹកនាំចិន ទៅបំពេញទស្សនកិច្ចនៅកម្ពុជា។

ក្នុងឱកាសទស្សនកិច្ចនេះ ភាគីទាំងពីរបានរៀបចំវេទិកាសេដ្ឋកិច្ចកម្ពុជា-ចិន ស្តីពីវិស័យទេសចរណ៍ វិនិយោគ និងពាណិជ្ជកម្ម និងបានចុះហត្ថលេខាលើឯកសារកិច្ចសហប្រតិបត្តិការក្នុងវិស័យកិច្ចការការបរទេស កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការនាំចេញកសិផលទៅកាន់ប្រទេសចិន ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ ប្រព័ន្ធផ្សព្វផ្សាយ និងការការពារបេតិកភណ្ឌវប្បធម៌។ល។

ទីក្រុងប៉េកាំង ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣